www.kidworship.kr


103Page


104Page


105Page


106Page


107Page


108Page

# លោកពេត្រុស
## (លោកពេត្រុសព្យាបាលបុរសពិការ)

ថ្ងៃមួយនៅពេលកំពុងតែអធិស្ឋាន លោកពេត្រុសនិងលោកយ៉ូហានបានឡើងទៅព្រះវិហារជាមួយគ្នា។ នៅខ្លោងទ្វារព្រះវិហារ ពួកគេបានឃើញបុរសពិការជើងម្នាក់ គាត់បានពិការជើងតាំងពីកំណើតមកម្លេះ គាត់ពុំធ្លាប់បានដើរទាល់តែសោះ។

---

ជារៀងរាល់ថ្ងៃគាត់បានមកសុំទាននៅមុខព្រះវិហារ។ កាលគាត់បានឃើញ លោកពេត្រុស និងលោកយ៉ូហានបានដើរចូលព្រះវិហារ នោះគាត់ក៏បានសុំប្រាក់ពីពួកគេ។ “សុំជួយខ្ញុំផង”។

---

ប៉ុន្តែលោកពេត្រុស និងលោកយ៉ូហានពួកគេគឺគ្មានប្រាក់នោះទេ  ដូច្នេះគាត់ក៏ពោលថា៖ “ សូមមើលមកយើង!” ។ បុរសពិការក៏បានក្រឡេកមើលទៅលោកពេត្រុសនិងលោកយ៉ូហាន រួចលោកពេត្រុសក៏មានប្រសាសន៍ទៅគាត់ថា៖ “ខ្ញុំគ្មានប្រាក់គ្មានមាសទេ តែអ្វីៗដែលខ្ញុំមាន ខ្ញុំនឹងឲ្យទៅអ្នក”។ បុរសពិការគាត់បានលាដៃរបស់គាត់ដោយរំពឹងថា គាត់នឹងទទួលបានរបស់ខ្លះពីពួកគេ។

---

នោះលោកពេត្រុសបាននិយាយទៅកាន់បុរសនោះថា៖ “ ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត ជាអ្នកភូមិណាសារ៉ែត ចូរក្រោកឡើង ហើយដើរទៅចុះ” លោកពេត្រុសបានចាប់ដៃស្តាំរបស់គាត់ ហើយឲ្យគាត់បានក្រោកឈរឡើង។

---

រំពេចនោះជើងរបស់គាត់និងសន្លាក់ ឆ្អឹងក៏ប្រែជាមាំមួន គាត់ក៏ស្ទុះឈរឡើងហើយអាចដើរបាន។ បន្ទាប់មកគាត់ក៏បានចូលទៅក្នុងព្រះវិហារជាមួយនឹងសិស្សទាំងពីរនាក់ ទាំងដើរផង លោតផង និងសរសើរតម្កើងព្រះជាម្ចាស់ផង។

---

នៅពេលដែលប្រជាជនបានឃើញបុរសពិការតាំងពីកំណើតអាចដើរបាន លោតបាននិងសរសើរតម្កើងព្រះជាម្ចាស់យ៉ាងដូច្នេះ ទើបពួកគេជឿថាគាត់ពិតជាបុរសពិការដែលតែងតែអង្គុយសុំទាននៅមុខព្រះវិហារពិតប្រាកដមែន។ “ មែនហើយ ពិតជាគាត់មែន! ខ្ញុំឆ្ងល់ណាស់ថា តើវាកើតឡើងដោយរបៀបណា?” ប្រជាជនបាននាំគ្នាងឿងឆ្ងល់និងខ្សឹបខ្សៀវពីការអស្ចារ្យនេះ។ បុរសពិការបាននៅជាប់ជាមួយ លោកពេត្រុស និងលោកយ៉ូហានជានិច្ច ហើយគាត់បានស្រែកថា៖ “គឺមនុស្សនេះហើយដែលជាអ្នកព្យាបាលជើងរបស់ខ្ញុំ” បណ្តាជនទាំងអស់បាននាំគ្នារត់ទៅចោមរោមមើល លោកពេត្រុសនិងលោកយ៉ូហាន។ ពេលលោកពេត្រុសឃើញដូច្នេះគាត់ក៏មានប្រសាសន៍ទៅបណ្តាជនថា៖ “ បងប្អូនទាំងអស់គ្នាអើយ ពួកយើងមិនបានព្យាបាលបុរសម្នាក់នេះទេ ពួកយើងក៏ដូចជាបងប្អូនទាំងអស់គ្នាដែរ គឺព្រះយេស៊ូជាព្រះរាជ្យបុត្រារបស់ព្រះជាម្ចាស់ទេតើ ដែលជាអ្នកព្យាបាលដល់គាត់។ លោកពេត្រុសបានលើកទឹកចិត្តដល់បណ្តាជនឲ្យផ្លាស់ប្រែចិត្តនិងទទួលជឿលើព្រះជាម្ចាស់។

---



109Page

នៅពេលដែលពួកគេកំពុងតែមានប្រសាសន៍នៅឡើយ នោះស្រាប់តែពួកបូជាចារ្យ, ពួកមេដឹកនាំ,
ពួកព្រឹទ្ធាចារ្យ និងអ្នកបង្រៀនខាងក្រិត្យវិន័យក៏បានមកដល់។
ពួកគេទាស់ចិត្តនឹងពួកសិស្សដែលបង្រៀនបណ្ដាជនពីមនុស្សស្លាប់នឹងរស់ឡើងវិញ
ដោយសំអាងលើការរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្ត។ ពេលនោះពួកគេបានចាប់
លោកពេត្រុសនិងលោកយ៉ូហានយកទៅឃុំ។
លុះថ្ងៃបន្ទាប់ពួកគេក៏នាំពេត្រុស និងយ៉ូហានមកឈរនៅមុខក្រុមប្រឹក្សាជាន់ខ្ពស់។ ពួកបូជាចារ្យ,
ពួកមេដឹកនាំ, ពួកព្រឹទ្ធាចារ្យ និងអ្នកបង្រៀនខាងក្រិត្យវិន័យបានសួរចម្លើយពួកគេ “
តើអ្នកធ្វើការនេះដោយសំអាងលើអំណាចអ្វី? ក្នុងនាមនរណា?” ពេត្រុសបានឆ្លើយតបដោយភាពក្លាហាន “
អ្នកមិនដែលបានស្ដាប់ព្រះយេស៊ូបានមានព្រះបន្ទូលឡើយ ប្រសិនបើអ្នកមិនព្រមធ្វើតាមពួកយើងទៀតនោះ
អ្នកនឹងមានបញ្ហាធំជាមិនខាន”  ប៉ុន្តែជាធម្មតាពួកយើងតែងតែស្ដាប់បង្គាប់ព្រះ។

..........................................................................................................................................



110Page

ទោះជាយ៉ាងណាលោកពេត្រុសគាត់គឺជាមនុស្សសាមញ្ញប៉ុណ្ណោះ ហើយពុំធ្លាប់បានរៀនសូត្រនោះទេ។
ប៉ុន្តែដោយប្រាជ្ញានៃព្រះ គាត់បានធ្វើឲ្យពួកគេនៅស្ងៀមរកអ្វីនិយាយមិនបាន នៅចំពោះបណ្ដាជនទាំងអស់។
ពួកបូជាចារ្យ, ពួកមេដឹកនាំ,ពួកព្រឹទ្ធាចារ្យ និងអ្នកបង្រៀនខាងក្រិត្យវិន័យមានការភ្ញាក់ផ្អើលជាខ្លាំង។
ពួកគេគ្មានអ្វីដែលត្រូវនិយាយទៅលោកពេត្រុសនិងលោកយ៉ូហានទៀតឡើយ។

..........................................................................................................................................



111Page

ពេលដែលបណ្ដាជនទាំងអស់បានឃើញហេតុការណ៍ផ្ទាល់ភ្នែក
ដែលបុរសពិការបានសរសើរតម្កើងព្រះជាម្ចាស់ នោះពួកគេក៏បានសរសើរតម្កើងព្រះជាម្ចាស់
និងចង់ស្ដាប់លោកពេត្រុស អធិប្បាយពីព្រះបន្ទូលរបស់ព្រះយេស៊ូ។